ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខៈ ១៦៦/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តស្ទឹងត្រែង"

នាព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តស្ទឹងត្រែង»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម ស្វាយ សំអ៊ាង អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តស្ទឹងត្រែង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យ ដែលរដ្ឋបាលខេត្តស្ទឹងត្រែង ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

### I. ស្ថានភាពទូទៅ

ខេត្តស្ទឹងត្រែង បែងចែកចេញជា ៦ក្រុង-ស្រុក ៣៤ឃុំ-សង្កាត់ និង១៣៧ភូមិ ដែលមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១៧១.២០៧នាក់ ស្មើនឹង ៤០.៨៨២គ្រួសារ។ សេដ្ឋកិច្ចខេត្តមានទំហំប្រមាណ ២៣៤លានដុល្លារ ស្មើនឹង ១% នៃសេដ្ឋកិច្ចជាតិ ដោយប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ក្នុងនោះ ចំណូលជាមធ្យមរបស់ប្រជាជនម្នាក់ ស្មើនឹង ១.៥៨៥ដុល្លាអាមេរិក អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយមកត្រឹម ២១%។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ជីវភាពរស់នៅ សម្រាលទុក្ខលំបាករបស់ប្រជាពលរដ្ឋ នៅពេលសង្គមជាតិមានវិបត្តិទាំងជំងឺកូវីដ-១៩ ក៏ដូចជាគ្រោះមហន្តរាយធម្មជាតិផ្សេងៗ។ គិតមកដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ខេត្តបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដែលបានជួយដល់គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំ ព្រមទាំងប្រជាពលរដ្ឋងាយរងហានិភ័យដោយសម្ពាធអតិផរណា ចំណាយថវិកាសរុបចំនួន ៦០.២៩៥.៦៩៧.៧០០រៀល។
- **វិស័យកសិកម្ម៖** ជាវិស័យអាទិភាពមួយក្នុងខេត្ត ដែលដើរតួយ៉ាងសំខាន់ក្នុងការធានាបាននូវសន្តិសុខស្បៀង និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ខេត្តមានផ្ទៃដីដាំដុះដំណាំកសិកម្មប្រមាណជាង ១០០.០០០ហិកតា ក្នុងនោះ ដំណាំស្រូវ ២៧.០០០ហិកតា ស្វាយចន្ទី ៤៤.៥២៧ហិកតា កៅស៊ូ ១៣.៣៤១ហិកតា ដំឡូងមី ២៥.០៦៧ហិកតា ស្វាយ ៣.៩៨០ ហិកតា និងដំណាំរួមផ្សំផ្សេងៗ ៤.០០០ហិកតា។ ដោយក្នុងមួយឆ្នាំៗ ចំណូលជាមធ្យមដែលទទួលបានពីទិន្នផលកសិកម្មនេះ ក្នុងរង្វង់ ១៤០ ទៅ ១៦០លានដុល្លាអាមេរិក។ ជាមួយគ្នានេះ ក៏បានខិតខំពង្រឹង និងពង្រីកប្រព័ន្ធធារាសាស្ត្រក្នុងមូលដ្ឋាន ក្នុងន័យទ្រទ្រង់ការស្រោចស្រពផ្ទៃដីកសិកម្ម ព្រមទាំងបម្រើដល់ការប្រើប្រាស់ជាប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋផងដែរ។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ និងការផ្តល់សេវាសាធារណៈ៖** រដ្ឋបាលខេត្ត បានរៀបចំកងកម្លាំងជាប្រចាំ ក្នុងការគ្រប់គ្រង ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ព្រមទាំងជំរុញ និងប្រកាន់ខ្ជាប់នូវការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព បទល្មើសគ្រប់ប្រភេទត្រូវបានបង្ក្រាប និងកាត់បន្ថយជាបន្តបន្ទាប់ ជាពិសេសរដ្ឋបាលខេត្ត បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនៅជាប់ព្រំដែន សំដៅថែរក្សាសន្តិសុខព្រំដែន ជំរុញការអភិវឌ្ឍ និងការកាត់បន្ថយបទល្មើសឆ្លងដែនផងដែរ។ ជាមួយគ្នានេះ បានជំរុញនូវការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ចូលរួមចំណែកលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយភាពងាយស្រួល ទាន់ពេលវេលា និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ តាមរយៈយន្តការច្រកចេញ-ចូលតែមួយ បានផ្តល់សេវាជូនប្រជាពលរដ្ឋជាមធ្យមក្នុងមួយឆ្នាំៗ ប្រមាណជាង ៥.០០០សេវា។

- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** ដោយប្រើប្រាស់គម្រោងថវិកាខេត្ត មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ-សង្កាត់ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងខេត្ត មានការរីកចម្រើន និងអភិវឌ្ឍន៍គួរកត់សម្គាល់។ ជាមួយគ្នានេះ ការពង្រីកបណ្ដាញអគ្គិសនី ត្រូវបានតភ្ជាប់ទៅគ្រប់បណ្ដាឃុំ-សង្កាត់ទាំងអស់ទូទាំងខេត្ត ដោយអ្នកទទួលបានអគ្គិសនីប្រើប្រាស់មានចំនួន ១៥.៤៣៦នាក់។ ដោយឡែក ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ក៏ត្រូវបានពង្រីក ព្រមទាំងបានរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកទៅតាមបទដ្ឋានថ្មីក្នុងក្រុងស្ទឹងត្រែង និងទីប្រជុំជនមួយចំនួនទៀត ដែលមានសមត្ថភាពផ្គត់ផ្គង់ទឹក ១២ ទៅ១៥ពាន់ម៉ែត្រគូប ក្នុងមួយថ្ងៃ។
- **វិស័យទេសចរណ៍៖** ខេត្តសម្បូរទៅដោយធនធានធម្មជាតិ ព្រៃភ្នំ ទន្លេ ដីកោះ តំបន់ជីវៈចម្រុះ និងតំបន់ការពារធម្មជាតិ ដែលជាសក្តានុពលមួយក្នុងការទាក់ទាញភ្ញៀវទេសចរផងដែរ។ ខេត្តមានមូលដ្ឋាន និងសហគមន៍អេកូទេសចរណ៍ធម្មជាតិ ប្រវត្តិសាស្ត្រ និងវប្បធម៌សំខាន់ៗ ចំនួន ១២កន្លែង អាចទាក់ទាញភ្ញៀវទេសចរជាមធ្យមប្រមាណ ១២០.០០០ ទៅ ១៦០.០០០នាក់ ក្នុងមួយឆ្នាំៗ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានប្តេជ្ញាបន្តថែរក្សា ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឱ្យបានកាន់តែរឹងមាំ និងពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ធានាបាននូវការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទ។ ជំរុញផែនការលើកកម្ពស់វិស័យកសិកម្ម កសិ-ឧស្សាហកម្ម ទេសចរណ៍ តាមរយៈការអប់រំ បណ្តុះបណ្តាលជំនាញបច្ចេកទេសពិតប្រាកដដល់ប្រជាជន លើកកម្ពស់ការរស់នៅ កាត់បន្ថយការចំណាកស្រុក ពង្រឹងការងារនៅមូលដ្ឋាន។ បន្តជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ឱ្យកាន់តែមានប្រសិទ្ធភាព លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ព្រមទាំងបន្តពិនិត្យ និងដោះស្រាយសំណើរ សំណូមពរ បញ្ហាប្រឈមនានា ជាពិសេសបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាប់តំបន់ព្រំដែន ធានាបាននូវអធិបតេយ្យភាពជាតិ បូរណភាពទឹកដី ព្រមទាំងបង្កើនការវិនិយោគ និងអភិវឌ្ឍន៍នៅតាមតំបន់ព្រំដែនផងដែរ។

ថ្ងៃចន្ទ ៥កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣